ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខៈ ២៨២ រជ.បល.លាន

# បទប្បញ្ញត្តិ
# សម្រាប់បេក្ខជនប្រឡងប្រជែងចូលបម្រើការងារ
# ជាមន្ត្រីរាជការក្នុងក្របខណ្ឌក្រសួងរ៉ែ និង ថាមពល

ដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ និងវិន័យក្នុងពេលប្រឡងឱ្យប្រព្រឹត្តទៅបានល្អប្រសើរ បេក្ខជនត្រូវគោរពបទប្បញ្ញត្តិនៃការប្រឡងប្រជែង ដូចមានខ្លឹមសារខាងក្រោមៈ

## ១- ប្រការដែលបេក្ខជនត្រូវអនុវត្ត

- ត្រូវមកដល់មណ្ឌលប្រឡង មុនការចាប់ផ្តើមដំណើរការប្រឡង រយៈពេល ៣០នាទី។
- ត្រូវស្លៀកពាក់សម្លៀកបំពាក់សមរម្យ។
- ត្រូវយកមកជាមួយនូវសលាកបត្រឯកត្តជន បង្កាន់ដៃទទួលពាក្យប្រឡង អត្តសញ្ញាណបណ្ណ ឬលិខិតសម្គាល់ខ្លួន។
- ត្រូវអនុវត្តតាមការណែនាំរបស់ក្រុមការងារមេប្រយោគ និង ក្រុមការងារអនុរក្ស។
- ត្រូវរក្សារបៀបរៀបរយ និង ភាពស្ងៀមស្ងាត់នៅពេលប្រឡង។
- បេក្ខជនត្រូវបង្កលក្ខណៈងាយស្រួលឱ្យអ្នកមានសមត្ថកិច្ចត្រួតពិនិត្យ និង ត្រូវគោរពតាមសំណូមពររបស់អ្នកត្រួតពិនិត្យក្នុងការដកហូតទុកនូវសម្ភារៈ ឬ របស់អ្វីៗ ដែលគ្មានការអនុញ្ញាតឱ្យយកចូលក្នុងបន្ទប់ប្រឡង។
- ត្រូវគោរពបទប្បញ្ញត្តិនៃការប្រឡង ដោយមិនត្រូវធ្វើឱ្យខូចរបៀបរៀបរយ និង សណ្តាប់ធ្នាប់នៃការប្រឡងឡើយ មានដូចជាៈ អង្គុយតាមលេខតុដែលអនុរក្សបង្ហាញ ប្រើប្រាស់ប៊ិចព័ណ៌ខៀវ សរសេរឈ្មោះ និង លេខតុនៅលើក្បាលសន្លឹកកិច្ចការប្រឡងដែលអនុរក្សចែកឱ្យ និង ប្រគល់សន្លឹកកិច្ចការប្រឡងដល់អនុរក្សវិញ ទោះបីសន្លឹកកិច្ចការប្រឡងគ្មានសរសេរចម្លើយ ឬ ដំណោះស្រាយអ្វីក៏ដោយ។ បេក្ខជន ដែលមិនប្រគល់សន្លឹកកិច្ចការប្រឡងជូនអនុរក្សវិញ នឹងត្រូវបានពិន្ទុសូន្យ។

## ២- ប្រការដែលបេក្ខជនមិនត្រូវអនុវត្ត

- ហាមដាច់ខាតការសេពគ្រឿងស្រវឹង។
- ហាមយកចូលក្នុងបន្ទប់ប្រឡង នូវសំណៅឯកសារគ្រប់រូបភាព
- ហាមយកអាវុធ ឬ គ្រឿងផ្ទុះគ្រប់ប្រភេទចូលក្នុងមណ្ឌលប្រឡង។
- ហាមយកតាម និង ប្រើប្រាស់ទូរស័ព្ទ និង វិទ្យុទាក់ទង ព្រមទាំងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទដែលមានផ្ទុកឯកសារ ចូលក្នុងបន្ទប់ប្រឡង លើកលែងតែម៉ាស៊ីនគិតលេខ។
- មិនត្រូវឱ្យអ្នកដទៃប្រឡងជំនួសឡើយ។
- ហាមចម្លងពីអ្នកជិតខាង ឬ បង្កលក្ខណៈឱ្យអ្នកដទៃចម្លង ឬ សរសេរហើយអានខ្លាំងៗ ដែលនាំឱ្យឮដល់បេក្ខជនដទៃទៀត ក្នុងពេលកំពុងធ្វើវិញ្ញាសា។

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom Penh Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- ហាមប្ដូរសន្លឹកកិច្ចការប្រឡង ដើម្បីឱ្យអ្នកដទៃជួយកែ។
- មិនត្រូវស្នើឱ្យអ្នកដទៃជួយពន្យល់។
- ហាមប្រើទឹកលុបសម្រាប់លុបកំហុសផ្សេងៗ លើសន្លឹកកិច្ចការប្រឡង។
- មិនត្រូវធ្វើឱ្យចលាចលក្នុងមណ្ឌលប្រឡង។

***បញ្ជាក់៖*** រាល់ការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិខាងលើ កម្រិតវិន័យនឹងត្រូវបានកំណត់ដោយក្រុមការងារមេប្រយោគ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៧

**ជ.គណៈកម្មការប្រឡងប្រជែង**

**ប្រធាន**

**ប៉ែន ឆដា**